# របាយការណ៍ប្រចាំត្រីមាសទី ៣ ឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តឧត្តរមានជ័យ

## ១. សេចក្តីផ្តើម

ខេត្តឧត្តរមានជ័យស្ថិតនៅទិសឧត្តរនៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយប្រមាណ ៤៤១ គីឡូម៉ែត្រពីរាជធានីភ្នំពេញ មានផ្ទៃដីសរុបចំនួន ៦.៦៣១,៧២ គីឡូម៉ែត្រក្រឡា។ ខេត្តនេះមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តព្រះវិហារ ខាងលិចជាប់នឹង ខេត្តបន្ទាយមានជ័យ ខាងត្បូងជាប់នឹងខេត្តសៀមរាប និងខាងជើងប្រវែង ២២៥ គីឡូម៉ែត្រជាប់នឹងខេត្តស៊ីសាកេត ខេត្តបុរីរ៉ុំ និងខេត្តសុរិន្ទ្រ ប្រទេសថៃ និងមានស្រុកចំនួន ០៤ និងក្រុង ១ គឺស្រុកអន្លង់វែង ស្រុកត្រពាំងប្រាសាទ ស្រុកចុងកាល់ ស្រុកបន្ទាយអំពិល និងក្រុងសំរោង។

## ២. ស្ថានភាពរបស់មន្ទីរ

### ២.១ ការងាររដ្ឋបាល និងបុគ្គលិក

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តឧត្តរមានជ័យ ដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអមដោយអនុប្រធានមន្ទីរចំនួន ០២ រូប និងមាន បុគ្គលិកសរុបចំនួន ៣២ នាក់ ក្នុងនោះនៅកម្រិតរដ្ឋបាលថ្នាក់មន្ទីរមានការិយាល័យជំនាញចំនួន ០៨ និងថ្នាក់ស្រុក ០៥ ។

### ២.២ កិច្ចប្រជុំផ្សេងៗ និងទំនាក់ទំនងសាធារណៈ

- លោកប្រធានមន្ទីរ បានចូលរួមពិធីដាំដើមឈើអបអរសាទរបុណ្យរុក្ខទិវា ០៩ កក្កដា ឆ្នាំ២០១៥ នៅបរិវេណពហុកីឡាដ្ឋានខេត្ត។ ប្រជុំសាមញ្ញលើកទី ១៤ របស់ក្រុមប្រឹក្សាខេត្ត អាណត្តិទី២ (ចំនួន ០២ លើក) នៅសាលប្រជុំសាលាខេត្ត។ សិក្ខាសាលាថ្នាក់តំបន់ស្តីពី "ការផ្សព្វផ្សាយកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៥-២០១៨ នៅសណ្ឋាគារសុខាល័យអង្គរ ខេត្តសៀមរាប។ ពិធីជួបសំដែងការគួរសមជាមួយអភិបាលខេត្តស៊ីសាកេត នៃព្រះរាជាណាចក្រថៃ នៅសាលប្រជុំសាលាខេត្ត។ ពិធីប្រកាសក្រុមការងារទទួលខុសត្រូវ ដឹកនាំជំរុញ ផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ នៅសាលប្រជុំមន្ទីរទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច។ ជួបពិសារបាយសាមគ្គីជាមួយអភិបាលខេត្តបុរីរ៉ុំ នៃព្រះរាជាណាចក្រថៃ នៅច្រកទ្វារអន្តរជាតិជប់គគីរ។ ពិធីបញ្ចុះបឋមសិលាសាងសង់អាគារសិស្សាសាលាបឋមសិក្សាដងទង់និងពិធីបញ្ចុះបឋមសិលាសាងសង់សាលាធម្មសភាថ្មី។ពិធីសំណេះសំណាលនិវត្តន៍ជនមុខសញ្ញាអតីតយុទ្ធជន ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍ **គន់ គីម** ប្រធានក្រុមការងារថ្នាក់ជាតិ ចុះជួយខេត្ត នៅទីស្នាក់ការគណបក្សប្រជាជនកម្ពុជា ស្រុកចុងកាល់។ សិក្ខាសាលាស្តីពីការពង្រឹងសមត្ថភាពអនុវត្តថវិការកម្មវិធី របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅសណ្ឋាគារហ្គោលដិនស៊ី និងកាសុីណូ ខេត្តព្រះសីហនុ។
- ថ្នាក់ដឹកនាំមន្ទីរ ចូលរួមប្រជុំបូកសរុបលទ្ធផលការងារចុះវាស់វែងដីជូនប្រជាពលរដ្ឋ ចំណុចអូរអំពិល ភូមិអូរតាម៉េង ឃុំអន្លង់វែង ស្រុកអន្លង់វែង នៅសាលប្រជុំលេខ១២ សាលាខេត្ត។ ប្រជុំបូកសរុបលទ្ធផលប្រចាំខែមិថុនា របស់គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ (ចំនួន ០២ លើក) នៅសាលប្រជុំសាលាខេត្ត។ ប្រជុំស្តីពីការគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង ក្រោមអធិបតីភាព ឯកឧត្តម **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ នៅស្រុកអន្លង់វែង។ ប្រជុំពិនិត្យនិងការផ្តល់យោបល់លើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ២០១៥-២០១៧ របស់គណៈ

កម្មាធិការសម្របសម្រួលបច្ចេកទេស នៅសាលប្រជុំសាលាខេត្ត។ សិក្ខាសាលាស្តីពីការប្រើប្រាស់ឯកសារព័ត៌មាន និងឯកសារពិន្ទុវិស័យរាជធានី/ខេត្ត នៅខេត្តបាត់ដំបង។ ពិធីវេរទានវស្សា ប្រគេនព្រះសង្ឃគង់ចាំព្រះវស្សា ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនី **គន់ គីម** អគ្គមេបញ្ជាការរង និងជានាយសេនាធិការចំរុះ នៃកងយោធពលខេមរភូមិន្ទ និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះជួយខេត្តឧត្តរមានជ័យ នៅវត្តប្រាសាទរាជាសំរោង។ ពិធីប្រកាស់ក្រុមការងារទទួលខុសត្រូវដឹកនាំជិរុញផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ នៅសាលប្រជុំមន្ទីរទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច។ ពិធីប្រកាស់ដាក់ឱ្យអនុវត្តគោលនយោបាយជាតិ និងសកម្មភាពជាតិ ស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចឆ្នាំ២០១៤-២០១៨ នៅសាលប្រជុំធំសាលាខេត្ត។ ពិធីចែកអំណោយកាកបាទក្រហមកម្ពុជា ជូនដល់ប្រជាពលរដ្ឋក្រីក្រ នៅស្រុកចុងកាល់។ សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងផែនការសកម្មភាពកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយក្នុងវិស័យកសិកម្មសម្រាប់ខេត្តឧត្តរមានជ័យ នៅសណ្ឋាគារឈើនប្រាក់គប។

- មន្ត្រីការិយាល័យ ចូលរួមប្រជុំពិភាក្សាអំពីការបំពេញការងាររបស់មន្ត្រីរាជការ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ។ ពិធីយុទ្ធនាការអក្ខរកម្មជាតិឆ្នាំ២០១៨ នៅសាលប្រជុំសាលាខេត្ត។ សិក្ខាសាលាផ្សព្វផ្សាយផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហឹង្សាលើស្ត្រីឆ្នាំ ២០១៤-២០១៨ នៅសាលប្រជុំសាលាខេត្ត។ សិក្ខាសាលាប្រកាសផ្សព្វផ្សាយការចាប់ផ្តើមអនុវត្តគម្រោងសាកវប្បកម្មកម្ពុជា ដើម្បីបង្កើនប្រាក់ចំណូល និងអាហារូបត្ថម្ភ នៅសាលប្រជុំវិទ្យាល័យ ហ៊ុន សែន ឧត្តរមានជ័យ។ ប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាង "ស្តង់ដារភូមិទេចរណ៍គំរូ" នៅទីស្នាក់ការគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា រាជធានីភ្នំពេញ។ ប្រជុំ Pro TWG-H នៅសាលប្រជុំមន្ទីរសុខាភិបាលខេត្ត។ ពិធីបំពាក់កន្សែងដល់កាវីទ្ធិកម្ពុជា នៅសាលប្រជុំមន្ទីរទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអភិការកិច្ច។ ពិធីបំពាក់គ្រឿងឥស្សរិយយសការងារ ជូនបុគ្គលិកអប់រំ នៅសាលប្រជុំធំសាលាខេត្ត។ ប្រជុំបូកសរុបលទ្ធផលការងារចុះវាស់វែងដីជូនប្រជាពលរដ្ឋ នៅចំណុចអូរអំបិល ភូមិតាម៉េង ឃុំអន្លង់វែង នៅសាលប្រជុំលេខ ១២ សាលាខេត្តឧត្តរមានជ័យ។ ប្រជុំក្រុមបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ក្រោមជាតិ នៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត។ សិក្ខាសាលាពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងផែនការយុទ្ធសាស្ត្រ ០៥ ឆ្នាំ ស្តីពីការអភិវឌ្ឍធនធានមនុស្ស របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ។ ប្រជុំក្រុមការងារពិសេសថ្នាក់ខេត្ត សម្រាប់លុបបំបាត់ជម្ងឺគ្រុនចាញ់ នៅសាលប្រជុំមន្ទីរសុខាភិបាលខេត្ត។ ប្រជុំប្រចាំខែសីហា (គ.ក.ស.ក) នៅសាលប្រជុំសាលាខេត្ត។ សិក្ខាសាលាផ្សព្វផ្សាយថ្នាក់តំបន់លើកទី ០២ ស្តីពី "ការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម អភិក្រមគ្របដណ្តប់វិស័យពាណិជ្ជកម្ម នៅសណ្ឋាគារខេមរាបាត់ដំបង ១ ខេត្តបាត់ដំបង។ ប្រជុំពិនិត្យឡើងវិញអំពីវឌ្ឍនៈភាពនៃការអនុវត្តកម្មវិធីការលើកកម្ពស់អនាម័យជនបទ តាមរយៈវិទ្យុខេត្ត នៅសណ្ឋាគារស៊ីសុខាញ៉ូយក ខេត្តកំពង់ឆ្នាំង។ វគ្គបណ្តុះបណ្តាលដំបូង នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ។ ចូលរួមពលកម្មអនាម័យ ដើម្បីទីក្រុងស្អាតទាំងអស់គ្នា ក្រោមអធិបតីភាព ឯកឧត្តម ស ថាវី អភិបាលខេត្ត នៅវេទិការអុំទូក។

## ៣. លទ្ធផលសម្រេចបានតាមវិស័យ

### ៣.១ ការងារផ្លូវជនបទ

- បញ្ចប់ការងារក្រាលគ្រួសក្រហមសរុបប្រវែង ៩.៣៩៧ ម៉ែត្រ ក្រោមគម្រោងឧបត្ថម្ភស្បៀងបន្ទាន់ រួមមាន÷ នៅស្រុកបន្ទាយអំពិល ប្រវែង ២.៣៩៥ ម៉ែត្រ ស្រុកចុងកាល់ ៤០០ ម៉ែត្រ ស្រុកអន្លង់វែង ៣.៦៣២ ម៉ែត្រ និងក្រុងសំរោង ប្រវែង ២.៩៧០ ម៉ែត្រ
- បានជួសជុលផ្លូវថែទាំលក្ខណៈខួបឆ្នាំ២០១៥ ប្រវែង ៩.២០០ ម៉ែត្រ និងសាងសង់លូប្រអប់០៣ ប្រឡោះ ០១ កន្លែង និងលូភ្លោះ ០១ កន្លែង ចាប់ពីភូមិគោកមន ឃុំគោកមន ដល់ភូមិតាម៉ា ឃុំបេង ស្រុកបន្ទាយអំពិល
- ធ្វើបច្ចុប្បន្នភាព និងប្រមូលទិន្នន័យផ្លូវថ្មី នៅក្នុងស្រុកចុងកាល់ ស្រុកបន្ទាយអំពិល ក្រុងសំរោង និងស្រុកអន្លង់វែង បានប្រវែងចំនួន ២០២ ខ្សែ ស្មើនឹងប្រវែង ៣៥៤,៦៨៦ គីឡូម៉ែត្រ
- ធ្វើផែនការជួសជុលបន្ទាន់បានចំនួន ១៥ គម្រោង ស្មើនឹង ៣១,៧១៨ គ.ម នៅស្រុកចុងកាល់
- ជួសជុលផ្លូវបន្ទាន់ សម្រាប់ឆ្នាំ ២០១៥ នៅភូមិពង្រ ភូមិអំពិល ដល់ភូមិព្រៃនគរ ប្រវែង ៦.០០០ ម៉ែត្រ សម្រេចបានលទ្ធល ១០០ % និង
- ចុះត្រួតពិនិត្យជ្រើសរើសផ្លូវជួសជុលបន្ទាន់ នៅឃុំចុងកាល់ ស្រុកចុងកាល់ ចំនួន ០៤ គម្រោង។

## ៣.២ ការងារផ្គត់ផ្គង់ទឹកស្អាត

- សាងសង់អណ្តូងស្នប់ AFridev ២១ អណ្តូង នៅស្រុកបន្ទាយអំពិល ១២ និងស្រុកត្រពាំងប្រាសាទ ០៩ អណ្តូង រួមមាន÷

| | | |
|---|---|---|
| ១. ភូមិតាមាន់សែនជ័យ | ចំនួន ០២ អណ្តូង | ស្រុកបន្ទាយអំពិល |
| ២. កងពលតូចអន្តរាគមន៍លេខ ៤ | ចំនួន ០៧ អណ្តូង | ស្រុកបន្ទាយអំពិល |
| ៣. កងពលតូចអន្តរាគមន៍លេខ ៥ | ចំនួន ០៤ អណ្តូង | ស្រុកបន្ទាយអំពិល |
| ៤. កងពលតូចអន្តរាគមន៍លេខ៦ | ចំនួន ០៨ អណ្តូង | ស្រុកត្រពាំងប្រាសាទ |

- ប្រជុំថ្នាក់ខេត្តស្តីពីការត្រៀមរៀបចំកសាងផែនការសកម្មភាពសម្រាប់ការងារផ្គត់ផ្គង់ទឹក និងអនាម័យជនបទខេត្ត ២០១៤-២០១៨ សម្របសម្រួលដោយលោក ប្រិច រ៉ាមី អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត
- ជួសជុលអណ្តូងស្នប់ ១៣ រួមមាន ស្រុកបន្ទាយអំពិល ០៦ និងក្រុងសំរោង ចំនួន ០៧ អណ្តូង និងជួសជុលអណ្តូងស្នប់ VN6 នៅក្រុងសំរោង ១១ អណ្តូង និង
- សហការជាមួយគណៈកម្មការហិរញ្ញប្បទានមន្ទីរសុខាភិបាលខេត្ត ចុះត្រួតពិនិត្យ និងសំភាសន៍អ្នកជម្ងឺនៅមន្ទីរពេទ្យបង្អែកស្រុកអន្លង់វែង បាន ១៣ ភូមិ ០៤ ឃុំ ស្មើនឹង ៣២ នាក់ នឹងនៅស្រុកត្រពាំងប្រាសាទ បាន ០៣ ភូមិ ០២ ឃុំ ស្មើនឹង ១២ នាក់ គាំទ្រហិរញ្ញប្បទានដោយអង្គការមូលនិធិសមធម៌ (CHC)។

## ៣.៣ ការងារថែទាំសុខភាពជនបទ

- ត្រួតពិនិត្យ និងវាយតម្លៃពីការ ប្រតិបត្តិអនាម័យរបស់ សហគមន៍ នៅក្នុងភូមិគោលដៅចំនួន៣២ ភូមិ ០៣ ឃុំ ០២ ស្រុក (ក្រុងសំរោងមាន ០១ សង្កាត់ ១៤ ភូមិ និងស្រុកចុងកាល់ មាន ០២ ឃុំ ១៨ ភូមិ)។ សកម្មភាពនេះដោយមានការចូលរួមសហការពីអាជ្ញាធរភូមិ ឃុំ និងប្រជាពលរដ្ឋសរុបចំនួន ១.០២១ នាក់ ស្ត្រី ៦២៥ នាក់
- សម្របសម្រួលកិច្ចប្រជុំប្រចាំត្រីមាសថ្នាក់ឃុំ ស្តីពីកម្មវិធីទឹកស្អាត និងអនាម័យ ចំនួន ០២ លើក មានភូមិគោលដៅ សរុប ៤៣ ភូមិ ០៥ ឃុំ និង ០២ ស្រុក និងមានអ្នកចូលរួមសរុបចំនួន ២៥៦

នាក់ ស្ត្រី ៣៦ នាក់

- ប្រជុំអប់រំផ្សព្វផ្សាយស្តីពីអនាម័យ នៅតាមភូមិគោលដៅ ដែលត្រូវបានទទួលនូវសម្ភារៈ សម្រាប់សាងសង់បង្គន់អនាម័យ ជាលក្ខណៈគ្រួសារ បានចំនួន ០២ លើក ក្នុងភូមិចំនួន ២០ ភូមិ ០៤ ឃុំ ០២ ស្រុក គឺស្រុកចុងកាល់ ឃុំពង្រ មាន ០៩ ភូមិ ឃុំចុងកាល់ មាន ០៧ ភូមិ និងស្រុកបន្ទាយអំពិល ឃុំបេង មាន ០៤ ភូមិ ឃុំគោកមន មាន ០៤ ភូមិ
- ត្រួតពិនិត្យ ជំរុញ និងអប់រំផ្សព្វផ្សាយពីការប្រតិបត្តិអនាម័យនៅតាមសហគមន៍ ក្នុងភូមិគោលដៅចំនួន ៣២ ភូមិ ០៣ ឃុំ ០២ ស្រុក (ក្រុងសំរោងមាន ០១ សង្កាត់ ១៤ ភូមិ និងស្រុកចុងកាល់ មាន ០២ ឃុំ ១៨ ភូមិ ) និង
- រៀបចំកម្មវិធីអប់រំផ្សព្វផ្សាយ ការលើកកម្ពស់អនាម័យ តាមរយៈវិទ្យុ ក្នុងកម្មវិធីសំនួរ-ចម្លើយ បានចំនួន ០៣ លើក សម្របសម្រួលដោយស្ថានីយ៍វិទ្យុ ជាតិប្រាសាទតាមាន់ FM 90.00 MHz ការផ្សាយគ្របដណ្តប់បានចំនួន ០៨ ស្រុក ០២ ខេត្ត (០៥ ស្រុក ក្នុងខេត្តឧត្តរមានជ័យ និង ០៣ ស្រុក ក្នុងខេត្តសៀមរាប)។

### ៣.៤ ការងារអភិវឌ្ឍន៍ភូមិដែនដីសខាងជើង និងខាងលិចប្រទេស

#### ៣.៤.១ ការងារសាងសង់ផ្ទះ÷

ភូមិតាមាន់សែនជ័យ ផ្ទះចំនួន ៣៧ ខ្នង បានបញ្ចប់រួចរាល់ ១០០%។

#### ៣-៤.២ ការងារសាងសង់ផ្លូវ (អនុវត្តដោយនាយកដ្ឋានផ្លូវលំជនបទ)÷

- ភូមិតាមាន់សែនជ័យ÷ ផ្លូវក្រាលគ្រួសក្រហម០១ខ្សែ មាន ០៥ កំណាត់ ប្រវែង ៨.៤០០ម៉ែត្រ ទទឹង ០៥ ម៉ែត្រ សំណង់សិល្បការគ្រប់ប្រភេទ ២៧ កន្លែង ចាក់ដីស ៩០% សាងសង់លូប្រអប់បាន ៦០% និងលូមូលបាន ៧៥% សម្រេចបានលទ្ធផល ៩០%
- ភូមិប្រាសាទក្រហមសែនជ័យ÷ ផ្លូវក្រាលគ្រួសក្រហមមាន ០៧ កំណាត់ ប្រវែងសរុប ១២.០០០ ម៉ែត្រ ទទឹង ៥ ម៉ែត្រ (ផ្លូវមេប្រវែង ៤.៥០០ ម៉ែត្រ ) និងលូមូលចំនួន ២០ កន្លែង សម្រេចបានលទ្ធផល ៩០% និង
- ភូមិពពេលសែនជ័យ÷ ផ្លូវក្រាលគ្រួសក្រហម ០១ ខ្សែ ៣.៦០០ ម៉ែត្រ ចាក់ដីសបាន ១០០% ក្រាលគ្រួសក្រហមបាន ៩០% សាងសង់សំណង់សិល្បការបាន ៥០%។

## ៤. ទិសដៅការងារបន្ត

- ចុះតាមដានត្រួតពិនិត្យការអនុវត្តផ្លូវថ្នល់ដុលបន្ទាន់ឆ្នាំ ២០១៥ នៅឃុំចុងកាល់
- ចុះប្រមូលទិន្នន័យខ្សែផ្លូវសាងសង់ថ្មី និងសំណង់សិល្បៈការ (សារពើភ័ណ្ឌផ្លូវ)
- ចុះតាមដានត្រួតពិនិត្យការងារកំពុងអនុវត្ត ថែទាំខួបឆ្នាំ២០១៥
- រៀបចំសម្របសម្រួលកិច្ចប្រជុំត្រីមាសថ្នាក់ឃុំ ស្តីពីកម្មវិធីទឹកស្អាត និងអនាម័យ
- រៀបចំកិច្ចប្រជុំប្រចាំត្រីមាស ស្តីពីកម្មវិធីទឹកស្អាត និងអនាម័យជនបទ ជាមួយអង្គការដៃគូរ និងស្ថាប័នពាក់ព័ន្ធ
- រៀបចំកម្មវិធីអប់រំផ្សព្វផ្សាយការលើកកម្ពស់អនាម័យ នៅជនបទតាមរយៈវិទ្យុ និង
- ចុះត្រួតពិនិត្យ និងជម្រុញការសាងសង់បង្គន់អនាម័យនៅតាមគ្រួសារ។